ធ៩-៩៨-៤១៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ប្រភពទុនជាប្រាក់បញ្ញើសម្រាប់ប្រើប្រាស់ក្នុងស្រុក
# របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

**ប្រការ ១**.-

ដាក់ចេញនូវវិធានការទប់ស្កាត់ការបញ្ចេញទៅក្រៅប្រទេសនូវប្រភពទុនជាប្រាក់បញ្ញើដែលកេណ្ឌប្រមូលបានក្នុងស្រុករបស់គ្រឹះស្ថានធនាគារ (ធនាគារពាណិជ្ជ) និងគ្រឹះស្ថានហិរញ្ញវត្ថុក្រោមឱវាទធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យសញ្ច័យក្នុងស្រុកអាចបម្រើផ្នែកវិនិយោគក្នុងប្រទេសបានទាំងស្រុង។

**ប្រការ ២**.-

រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវរក្សាទុកទាំងអស់ (១០០ ភាគរយ) នូវប្រាក់បញ្ញើដែលកេណ្ឌប្រមូលបានពីអតិថិជន និងប្រាក់បញ្ញើអន្តរធនាគារ សម្រាប់ការប្រើប្រាស់របស់ខ្លួននៅក្នុងប្រទេស។

សក្ខីកម្មនៃការរក្សាទុកនេះ ត្រូវបានឆ្លុះបញ្ចាំងដោយចំនួនសរុបនៃខ្ទង់ប្រាក់មួយចំនួននៅខាងទ្រព្យសកម្មនៃ តារាងតុល្យការដូចខាងក្រោម ៖

- សាច់ប្រាក់នៅក្នុងដៃ
- ប្រាក់បញ្ញើនៅធនាគារក្នុងស្រុក
- ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា (ដកចេញនូវប្រាក់ដំកល់ធានាចំនួន ១០ ភាគរយនៃដើមទុន)
- និងប្រាក់ឱ្យខ្ចីចងការ និងបុរេប្រទាន

ជានិច្ចកាល ចំនួនសរុបនេះយ៉ាងហោចណាស់ត្រូវតែស្មើនឹងប្រាក់បញ្ញើសរុបដែលកេណ្ឌប្រមូលបានពីអតិថិជន និងប្រាក់បញ្ញើជាអន្តរធនាគារ។

**ប្រការ ៣**.-

នៅរៀងរាល់ខែ រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានត្រួតពិនិត្យ) នូវតារាងគណនាដែលបានចែងនៅប្រការ ២ ដោយភ្ជាប់ជាមួយរបាយការណ៍ប្រចាំខែ ស្តីពីទ្រព្យសកម្ម និងទ្រព្យអកម្ម (តារាងតុល្យការ) ដែលធ្លាប់ផ្ញើមកជាប្រក្រតី។

ក្នុងករណីត្រួតពិនិត្យឃើញតារាងគណនានេះមិនឆ្លើយតបតាមលក្ខខណ្ឌដែលកំណត់នៅប្រការ ២ សាមីគ្រឹះស្ថាន ត្រូវរងការផាកពិន័យចំនួន ១ ភាគរយក្នុងមួយខែ លើចំនួនដែលខ្វះទុកជាការព្រមានលើកដំបូង សម្រាប់រយៈពេលមួយខែ ហួសពីនេះត្រូវរងវិធានការធ្ងន់ធ្ងរថែមទៀតតាមករណីជាក់ស្តែង។

**ប្រការ ៤**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៥**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៨ តទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**